ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន សាងវ៉ូ (ខេមបូឌា) ខូ អិលធីឌី

SANGWOO (CAMBODIA) CO., LTD

លេខ:......១០៥/៥.......ស.រ / ២០២០

SANGWOO

# កិច្ចព្រមព្រៀង

## ស្តីពី

## ការព្យួរកិច្ចសន្យាការងារដោយបញ្ហាសេដ្ឋកិច្ច (គ្មានការបញ្ជាទិញ)

កិច្ចព្រមព្រៀងនេះត្រូវបានព្រមព្រៀងធ្វើឡើងរវាង **ក្រុមហ៊ុនសាងវ៉ូ (ខេមបូឌា) ខូ អិលធីឌី** និងថ្នាក់ដឹកនាំ **សហជីពប្រតិភូបុគ្គលិកពេញសិទ្ធិ** នៃក្រុមហ៊ុនសាងវ៉ូ ដែលមានអាសយដ្ឋានស្ថិតនៅភូមិ **ថ្លក** ឃុំ **ត្រពាំងគង** ស្រុក **សំរោងទង** ខេត្ត **កំពង់ស្ពឺ** ដោយបានព្រមព្រៀងទាំងស្រុងលើការព្យួរកិច្ចសន្យាការងារដោយមូលហេតុៈ **បញ្ហាសេដ្ឋកិច្ច** (គ្មានការបញ្ជាទិញ) ហើយភាគីទាំងពីរបានព្រមព្រៀងគ្នាទៅតាមលក្ខខ័ណ្ឌ និងដោយយោងទៅតាមមាត្រាទី៧១ និងទី៧២ នៃច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម ៖

1. ព្រមព្រៀងព្យួរកិច្ចសន្យាការងារចំពោះ កម្មករ និយោជិតតាមផ្នែកខ្លះ ឬទាំងអស់ **ក្រោមរូបភាពឆ្លាស់វេន** ដោយអនុវត្តចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ។
2. នៅក្នុងកំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ភាគីនិយោជកយល់ព្រមផ្តល់អោយនូវៈ
    a. ផ្តល់ប្រាក់ឧបត្ថម្ភចំនួន **៣០ដុល្លារអាមេរិក** សម្រាប់កម្មករ និយោជិតម្នាក់ៗដែលព្យួរកិច្ចសន្យាការងារក្នុង១ខែ (យោងៈ សេចក្តីប្រកាសព័ត៌មាន ស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការបន្ថែម សំដៅជួយដល់វិស័យឯកជន និងកម្មករ និយោជិតដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជម្ងឺកូវីដ-១៩ " ជុំទី៣, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២០ " និងសេចក្តីណែនាំលេខ: ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០)

    b. ចំពោះកម្មករ និយោជិត ដែលព្យួរកិច្ចសន្យាការងារក្រោម០៧ថ្ងៃ ក្រុមហ៊ុនយល់ព្រមផ្តល់ប្រាក់ឧបត្ថម្ភចំនួន **៣០$** ដោយត្រូវគណនាផ្តល់ជូនជាសមាមាត្រទៅតាមថ្ងៃព្យួរកិច្ចសន្យាការងារជាក់ស្តែងនៅក្នុងខែនោះ

    c. ប្រាក់ឧបត្ថម្ភចំនួន **៣០ដុល្លារអាមេរិក** នឹងផ្តល់ជូនកម្មករ និយោជិតចំនួនពីរដងក្នុង១ខែតាមរយៈភ្នាក់ងារវីង និងធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA)

    d. ប្រាក់អត្ថប្រយោជន៍ផ្សេងៗ ត្រូវបានគណនាផ្តល់ជូនជាសមាមាត្រទៅតាមថ្ងៃធ្វើការជាក់ស្តែងនៃខែនីមួយៗ

សាងវ៉ូ (ខេមបូឌា) SANGWOO (CAMBODIA) CO., LTD.

3. ចំពោះនិយោជិតការិយាល័យ និងនិយោជិតបរទេសដែលព្យួរកិច្ចសន្យាការងារក៏ត្រូវទទួលបាន ៣០ **ដុល្លារអាមេរិក** ដូចគ្នាផងដែរនៅកំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ។

កិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃសៅរ៍ ០៣រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅកំពង់ស្ពឺ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០២០

**តំណាងកម្មករ និយោជិត និងសហជីព**

**នាយកក្រុមហ៊ុន**

SANGWOO (CAMBODIA) CO., LTD.

Mr. **WISOO JANG**

1043 641 1743

0824 18063 239 32864 20447

4796 21106